# ព្រះវិហារទ្រុឌទ្រោមនៅក្នុងវត្តត្នោត

ស្ថិតនៅលើទឹកដីនៃឃុំកោះសូទិន ស្រុកកោះសូទិន ខេត្តកំពង់ចាម មានវត្តមួយឈ្មោះវត្តត្នោត (ឬវត្តពោធិរិទ្ធិ) គឺជាវត្តដែលមានព្រះវិហារចាស់ថ្មីពីរសាងឡើងទន្ទឹមគ្នានៅតាមបណ្តោយដងទន្លេមេគង្គ។ បច្ចុប្បន្នព្រះវិហារចាស់ក្នុងវត្តនេះពុំបានប្រើប្រាស់ធ្វើកិច្ចប្រតិបត្តិគោរពបូជាដូចប្រមាណជាង២០ឆ្នាំមុនទៀតឡើយ ហើយគេសង្កេតឃើញថាព្រះវិហារនេះកំពុងស្ថិតក្នុងសភាពទ្រុឌទ្រោម ពុកបាក់បែក ស្មៅព្រៃដុះរុំស្រោប និងដុះធ្លាយដំបូលដោយអន្ទើ(រូបលេខ១-២)។ ប៉ុន្តែបើពិនិត្យលក្ខណៈសិល្បៈស្ថាបត្យកម្ម គ្រឿងលម្អលើសំណង់ គំនូរពុទ្ធប្រវត្តិ និងចំណារកត់ត្រាផ្សេងៗ នាំឱ្យគេយល់ថាព្រះវិហារចាស់ក្នុងវត្តត្នោតនេះសាងឡើងនៅពាក់កណ្តាលសតវត្សរ៍ទី២០ ហើយកន្លងមកព្រះសង្ឃ និងអ្នកស្រុកតែងនាំគ្នាជួសជុលថែទាំជាហូរហែ ជាពិសេសបានជុសជុលច្រើននៅក្នុងសម័យសង្គមរាស្ត្រនិយម។ លុះដល់ឆ្នាំ២០០៨ វត្តត្នោតបានសាងព្រះវិហារធំថ្មីមួយទៀតសម្រាប់ប្រើប្រាស់គោរពបូជាជំនួសព្រះវិហារចាស់ដែលតែងរងផលប៉ះពាល់ដោយគ្រោះធម្មជាតិនៃការបាក់ច្រាំងទន្លេ។



រូបលេខ១-២ ព្រះវិហារចាស់នៅវត្តត្នោត (ផ្នែកមុខ និងផ្នែកខាងក្រោយ)

បើផ្អែកតាមការស្រាវជ្រាវរបស់ Danielle និង Dominique-Pierre Guéret យល់ឃើញថាព្រះវិហារចាស់នៅក្នុងវត្តត្នោតកសាងតាំងពីឆ្នាំ១៩៥០។[1] គិតមកដល់សព្វថ្ងៃព្រះវិហារនេះ ជាសំណង់បេតិកភណ្ឌដ៏មានតម្លៃ ហើយបានឆ្លុះបញ្ចាំងពីសិល្បៈស្ថាបត្យកម្មអំឡុង

[1] Danielle & Dominique-Pierre Guéret; 2017, p. 112

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ចុងសម័យអាណាព្យាបាលបារាំង ដែលជាការចាប់ផ្ដើមរួមបញ្ចូលគ្នារវាងទម្រង់សិល្បៈប្រពៃណីខ្មែរ និងឥទ្ធិពលសម្ភារៈសំណង់ថ្មីៗ។ នៅលើបរិវេណខឿនទី២ គេឃើញមានចេតិយបុរាណជាទម្រង់ចេតិយលាត សាងឡើងនៅតាមជ្រុងទាំង៤ ចម្លាក់តោ១គូ ខាងមុខព្រះវិហារ និងមានខ្លោងទ្វារតាមទិសទាំង៤។ ចំណែកនៅតាមបង្កាន់ដៃជណ្ដើរឡើងផ្នែកខាងមុខ មានផ្ទាក់លម្អជារូបក្បាលដំរី និងកេឬស្ការ(?) ដ៏រស់រវើកគួរឱ្យចាប់អារម្មណ៍ (រូបលេខ៣-៧)។ សូមបញ្ជាក់ថា នៅលើខឿនថ្នាក់ទី១ ខាងក្រោយព្រះវិហារ អមជណ្ដើរផ្នែកខាងឆ្វេងមានចារ "ពុទ្ធសករាជ២៥០៤" ហើយផ្នែកខាងស្ដាំជណ្ដើរចារ "គ្រិស្តសករាជ១៩៦១"។ កាលបរិច្ឆេទនេះ ទំនងបញ្ជាក់ពីការសាងបញ្ចប់ខឿនព្រះវិហារ ក្រោយសាងព្រះវិហារឡើងរយៈពេល១០ឆ្នាំ។



រូបលេខ៣-៧ រចនាសម្ព័ន្ធផ្សេងៗជុំវិញបរិវេណព្រះវិហារវត្តត្នោត

ព្រះវិហារចាស់វត្តត្នោត ជាសំណង់រចនាបថព្រះវិហារបុរាណ ដែលមានលក្ខណៈពិសេសលេចធ្លោលើផ្នែកសិល្បៈតុបតែងលម្អ។ សំណង់នេះប្រើប្រាស់សសរឈើនៅផ្នែកខាងក្នុងមានចំនួន២៨ដើម ហើយនៅលើផ្ទៃសសរមួយចំនួនមានពាសម្រ័ក្សណ៍ និងបិទ

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មាសសន្ទឹក ដែលជាសិល្បៈដ៏វិសេសពេញនិយមក្នុងសំណង់ព្រះពុទ្ធសាសនា។[2] បើផ្អែកតាមការសិក្សាអំពីសំណង់នៅតាមវត្ត ព្រះវិហារនេះគេចាត់ថ្នាក់ទៅជាទម្រង់ជហ្វាបួន ឬហៅទូទៅថាព្រះវិហារបុរាណ។[3] ព្រះវិហារនេះប្រក់ក្បឿងស្រកាលេញ ហើយគ្រឿងលម្អស្ថាបត្យកម្មផ្នែកដំបូលរួមមាន ជហ្វា និងនាគបែងខ្លះបានបាក់បែកធ្លាក់ខូចដោយអន្ទើ។ ខាងមុខមានទ្វារចូលមួយយ៉ាងធំ ខាងក្រោយមានទ្វារពីរ ហើយចំហៀងនីមួយៗមានទ្វារម្ខាងបួន ដែលនេះអាចរាប់ថាជាលក្ខណៈពិសេសនៃព្រះវិហារវត្តត្នោត ពោលគឺពុំមានបង្អួចដូចបណ្ដាព្រះវិហារដទៃឡើយ។ តាមទ្វារទាំងអស់លម្អដោយក្បាច់ក្បាំង និងស៊ុមទ្វារពណ៌ទឹកប្រាក់យ៉ាងរស់រវើក។ សន្ទឹកទ្វារនីមួយៗជាបន្ទះក្ដារលាត គ្មានក្បាច់លម្អ គ្មានលាបពណ៌ ហើយសន្ទឹកទ្វារខ្លះបានពុកផុយបាក់ជ្រុះទាំងស្រុង។ ចំណែកឯសសរបាំងសាចជុំវិញព្រះវិហារ ដែលទល់ទ្រពិតានបេតុងខាងលើ គឺជាសសរបេតុងលាតរាងបួនជ្រុង លម្អដោយកិន្នរទ្រចុងពិតាននៅក្បាលសសរ ដែលទំនងសាងបន្ថែមក្នុងពេលណាមួយ។ សូមបញ្ជាក់ថា ពិតានបេតុងនៃព្រះវិហារនេះមានតែត្រង់បាំងសាចជុំវិញព្រះវិហារប៉ុណ្ណោះ ពិតានខាងក្នុងព្រះវិហារផ្នែកខាងលើល្វែងគ្រឹះ គឺជាពិតានឈើ។

ចំពោះហោជាងទាំងពីរលើព្រះវិហារនេះ ប្រហែលជាសាងថ្មីជំនួសហោជាងចាស់ក្នុងសម័យណាមួយ។ ហោជាងទាំងពីរចនាលម្អដោយក្បាច់អង្គរ ជាប្រភេទសិល្បៈចម្លាក់ពុម្ពស៊ីម៉ង់ត៍។ ហោជាងមុខឆ្លាក់រូបទេពមួយអង្គគង់លើបាល្ល័ង្កត្រង់ផ្នែកណ្ដាល ដោយលើព្រះហស្តទាំងពីរមានកាន់គម្ពីរ(?) ខាងស្ដាំមានចំណារ"អរហំ" ហើយខាងឆ្វេងមានចំណារ "ន មោ ពុ ទ្ធា យ" (រូបលេខ៨)។ បើសម្រាយសេចក្ដីនៃពាក្យបាលីទាំង នេះ "អរហំ" មានន័យថា "ព្រះមានព្រះភាគ ជាបុគ្គលដែលគួរដល់ការគោរពបូជា"។ "ន មោ ពុ ទ្ធា យ" មានសេចក្ដីថា "នមស្ការថ្វាយបង្គំនៃខ្ញុំ ចូរមានដល់ព្រះដ៏មានព្រះភាគ(ព្រះពុទ្ធ)។[4] ហោជាងខាងក្រោយ ពុំមានចម្លាក់អ្វីកត់សម្គាល់ឡើយ ពោលគឺមានតែការរចនាក្បាច់អង្គរពេញ

---

[2] ព្រាប ចាន់ម៉ារ៉ា, ២០០៩-២០១០: ៣៨-៤១

[3] ព្រាប ចាន់ម៉ារ៉ា, ២០១៧: ១៣-២៣

[4] ក្នុងវិស័យអប់រំខ្មែរសម័យដើម គ្រូតែងបង្គាប់សិស្សឲ្យទន្ទេញឃ្លា "ន មោ ពុទ្ធា យ សិទ្ធំ" ដែលមានន័យថា "ដោយកិច្ចនមស្ការរបស់ខ្ញុំចំពោះព្រះពុទ្ធ សូមឱ្យខ្ញុំបានសម្រេចនូវសេចក្ដីប្រាថ្នាទាំងពួង"។

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ហោជាងតែម្ដង។ គួរកត់ចំណាំថាសិល្បៈចម្លាក់លើហោជាងទាំងពីពុំមានលាបពណ៌លម្អអ្វីឡើយ ពោលគឺជាពណ៌ស៊ីម៉ងត៍ទាំងអស់ (រូបលេខ៨-៩)។

ខាងក្នុងព្រះវិហារមានក្រាលការ៉ូបុរាណ ហើយគេសង់ឡើងដោយចែកជា៣ល្វែង គឺល្វែងគ្រឹះនៅកណ្ដាល អមដោយរបៀងសងខាង ព្រមទាំងមានសសរឈើមូលធំៗចំនួន ២៨ដើម (សសរ២ជួរអមល្វែងគ្រឹះ និង២ជួរនៅតាមជញ្ជាំង)។ សសរខ្លះគេសង្កេតឃើញមានសេសសល់ស្នាកស្នាមលាបម្រ័ក្សណ៍ និងបិទមាស។ ប៉ុន្តែសព្វថ្ងៃសសរមួយចំនួនធំក្នុងចំណោមសសរទាំងនោះ បានប្រេះរហែក ហើយសសរខ្លះទៀតត្រូវកណ្ដៀរស៊ីពុកដាច់ជើងសសរទាំងស្រុង។ ក្នុងចំណោមសសរខាងក្នុងព្រះវិហារ គេឃើញមានសសរ២ដើម ចារឈ្មោះ ឯកឧត្ដម តាវ សេងហួរ ជាសមាជិករាជរដ្ឋាភិបាល និងលោកជំទាវ ព្រមទាំងគ្រួសារ ជាម្ចាស់សទ្ធាសាងសសរ។ ក្រៅពីនោះគឺជាឈ្មោះអ្នកស្រុកជិតឆ្ងាយដែលចេញប្រាក់សាងសសរនីមួយៗ (រូបលេខ១០-១១)។




*រូបលេខ៨-៩ ហោជាងខាងមុខ និងហោជាងខាងក្រោយនៃព្រះវិហារវត្តត្នោត*




*រូបលេខ១០-១១ ផ្នែកខាងក្នុងព្រះវិហារវត្តត្នោត*

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

ដោយឡែក ចំពោះព្រះជីវ័តម្កល់ក្នុងព្រះវិហារវត្តត្នោត គឺស្ថិតនៅខាងចុងនៃល្វែងគ្រឹះ។ ព្រះបដិមាតម្កល់លើបល្ល័ង្កខ្ពស់ ដែលមានខឿនបល្ល័ង្ក២ថ្នាក់។ ផ្អែកតាមការសិក្សាកាយវិការព្រះពុទ្ធបដិមា គេសម្គាល់ថា ជាកាយវិការព្រះពុទ្ធផ្ចាញ់មារ ទ្រង់ដាក់ព្រហស្តស្តាំដោយម្រាមទាំងប្រាំសណ្តូកស្របគ្នា ហើយលាតទៅប៉ះដី យកព្រះធរណីជាសាក្សី (រូបលេខ១២)។[5]



រូបលេខ១២ ព្រះបដិមាព្រះជីវ័ក្នុងព្រះវិហារចាស់វត្តត្នោត

ចំណែកគំនូរខាងក្នុងព្រះវិហារមានពីរផ្នែក គឺគំនូរលើជញ្ជាំងនិងគំនូរលើពិតាន (រូបលេខ១៣)។ គំនូរនៅលើជញ្ជាំងរៀបរាប់សាច់រឿងក្នុងពុទ្ធប្រវត្តិ ដោយនៅតាមជ្រុងជញ្ជាំងទាំង៤គេគូរជា២ជួរលើក្រោម។ គំនូរចាប់ផ្តើមពីព្រះអង្គទ្រង់ចាប់បដិសន្ធិ (សុបិននិម្មិត) រហូតទ្រង់បរិនិព្វាន និងចែកព្រះសារីរិកធាតុ។ លក្ខណៈពិសេសនៃគំនូរនេះ គឺមានចំណុចខ្វះបានបញ្ចូលនូវទិដ្ឋភាព និងសម្លៀកបំពាក់សង្គមខ្មែរមួយចំនួនដូចជា វត្តមាន

[5] សូមអាន៖ មាស សុភាព "កាយវិការព្រះពុទ្ធក្នុងសិល្បៈខ្មែរ" ផ្សាយលើគំណ https://khmercivilization.ams.com.kh/detail/15258 (១២ វិច្ឆិកា ២០២១)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

មន្ត្រីរាជការ និងកងទ័ព ត្រង់អន្ទើព្រះអង្គបរិនិព្វាន សម្ដែងឫទ្ធិ និងពិធីអភិសេកជាដើម (រូបលេខ១៤-១៥)។ ទន្ទឹមនេះ បើមើលលើទិដ្ឋភាពផ្សេងៗទៀត ព្រមទាំងពិនិត្យលើក្បាច់លម្អលើសសរ និងផ្ទឹមព្រះវិហារ រួមទាំងតម្លៃជាវគំនូរតាមផ្ទាំងនីមួយៗផង គេយល់ថាគំនូរទាំងនេះប្រហែលគូរឡើង(ឬគូរឡើងវិញ?)ក្នុងទសវត្សរ៍ទី៩០។ ប៉ុន្តែយ៉ាងណាក្ដីគេពុំឃើញមានចំណារឈ្មោះជាងគំនូរ ឬកាលបរិច្ឆេទគូរគំនូរទាំងនោះឡើយ។ ចំណែកឯគំនូរលើពិតានឈើខាងលើល្វែងគ្រឹះ មានតែរូបព្រះអាទិត្យ ព្រះចន្ទ្រ និងព្រះពុទ្ធ៥ព្រះអង្គ។ ប៉ុន្តែផ្នែកខាងលើសន្និយាព្រះដីរ៍ មានគំនូរមួយផ្ទាំងទៀតគូរអំពីព្រះពុទ្ធមង្គល ដែលពុំសូវប្រទះនៅតាមបណ្ដាព្រះវិហារផ្សេង (រូបលេខ១៦)។



រូបលេខ១៣-១៦ ស្ថានភាពនិងការរៀបចំគំនូរសាច់រឿងពុទ្ធប្រវត្តិលើជញ្ជាំង និងពិតានព្រះវិហារវត្តត្នោត

សរុបមកព្រះវិហារចាស់នៅក្នុងវត្តត្នោត គឺជាសំណង់បេតិកភណ្ឌដ៏មានតម្លៃ និងជាសក្ខីភាពនៃសិល្បៈស្ថាបត្យកម្មចុងសម័យអាណាព្យាបាលបារាំង។ ព្រះវិហារដហ្វាប្អូននេះមានលក្ខណៈពិសេសលេចធ្លោខុសប្លែកពីព្រះវិហារដទៃ មានទ្វារជុំវិញ (គ្មានបង្អួច)

អត្ថបទដោយ៖ ហៀន សុវណ្ណមរកត

*មានគ្រឿងលម្អយ៉ាងរស់រវើក និងសសរឈើមូលធំៗ ដែលមានស្នាកស្នាមពាសម្រ័ក្សណ៍បិទមាសសន្ទឹក និងគំនូរពុទ្ធប្រវត្តិនាំមកនូវទិដ្ឋភាពឆ្លុះបញ្ចាំងពីសម្លៀកបំពាក់ និងសង្គមខ្មែរនាសម័យកាលនោះ។ ទោះជាយ៉ាងណា គ្រឿងបង្គុំសំខាន់ៗនៃព្រះវិហារនេះ ទាមទារឱ្យមានការយកចិត្តទុកដាក់ និងជ្រោមជ្រែងជួសជុលអភិរក្សជាបន្ទាន់។ ប្រសិនបើពុំមានវិធានការសង្គ្រោះទាន់ពេលវេលានោះទេ បេតិកភណ្ឌសិល្បៈដ៏កម្រ និងមានតម្លៃមិនអាចកាត់ថ្លៃបានមួយនេះ នឹងត្រូវវិនាសបាត់បង់ជារៀងរហូតពីទឹកដីនៃដងទន្លេមេគង្គ៕*

## ឯកសារយោង

*ព្រាប ចាន់ម៉ារ៉ា*

២០០៩-២០១០, "គំនូរបុក", *កម្រងអត្ថបទក្នុងបណ្ដាញព័ត៌មានវប្បធម៌ខ្មែរ, លេខ២៥.* ទំ.៣៨-៤១, Friends of Khmer Culture, ភ្នំពេញ

២០១៧, *សំណង់នៅតាមវត្ត,* ការផ្សាយរបស់អ្នកនិពន្ធ, ភ្នំពេញ

*មាស សុភាព*

២០២១, "កាយវិការព្រះពុទ្ធក្នុងសិល្បៈខ្មែរ", *AMS អរិយធម៌ខ្មែរ,* ផ្សាយលើតំណ https://khmercivilization.ams.com.kh/detail/15258 (១២ វិច្ឆិកា ២០២១)

Daniell Guéret & Dominique-Pierre Guéret

2017, *The Khmer Pagoda,* Kam editions

*អត្ថបទដោយ៖ ហៀន សុវណ្ណមរកត*